( អនុម័ត )

*បកប្រែក្រៅផ្លូវការ*

# សេចក្តីថ្លែងការណ៍រួម
# នៃកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានលើកទី២៨ (28th ALMM)

ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤, ប្រទេសសិង្ហបុរី

---

១. កិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានលើកទី២៨ (ALMM) បានប្រារព្ធឡើងនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤ នៅប្រទេសសិង្ហបុរី។ កិច្ចប្រជុំនេះ ដឹកនាំដោយ ឯកឧត្តមបណ្ឌិត តាន់ ស៊ី ឡេង (Tan See Leng) រដ្ឋមន្ត្រីក្រសួងហត្ថពលកម្មនៃប្រទេសសិង្ហបុរី និងមានការចូលរួមពីតំណាងប្រទេសសមាជិកអាស៊ាន អគ្គលេខាធិការអាស៊ាន និងគណៈប្រតិភូអមដំណើររដ្ឋមន្ត្រីតាមប្រទេស។ តំណាងប្រទេសទីម័រឡេស្តេ បានចូលរួមក្នុងឋានៈជាអ្នកសង្កេតការណ៍។

២. ស្របពេលដែលរដ្ឋមន្ត្រីការងារអាស៊ានប្រារព្ធគម្រប់ខួបលើកទី៥០ នៃកិច្ចសហប្រតិបត្តិការ ចាប់តាំងពីខែមេសា ឆ្នាំ១៩៧៥ នៅទីក្រុងហ្សាការតា ជាមួយនឹងមូលបទ "ការពង្រឹងភាពធន់ និងការលើកកម្ពស់នវានុវត្តន៍" របស់ប្រទេសសិង្ហបុរី ក្នុងនាមជាប្រធាននៃកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានលើកទី២៨ យើងបានផ្លាស់ប្តូរទស្សនៈជុំវិញបញ្ហាជាមូលដ្ឋានពាក់ព័ន្ធនឹងវិស័យការងារ ដែលប្រទេសជាសមាជិកកំពុងជួបប្រទះ អំឡុងពេលនៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃបរិបទការងារសកល។ ភាពជឿនលឿននៃបច្ចេកវិទ្យា, សេដ្ឋកិច្ចឌីជីថល និងសេដ្ឋកិច្ចបៃតង, ការប្រែប្រួលប្រជាសាស្ត្រ និងការកើនឡើងនៃការធ្វើបម្លាស់ទីការងារ បាននាំមកជាមួយនូវបញ្ហាប្រឈម និងកាលានុវត្តភាពមួយចំនួន សម្រាប់ទីផ្សារការងារនៅក្នុងបណ្តាប្រទេសសមាជិកអាស៊ាន។ យើងក៏បានបញ្ជាក់ពីការរីកចម្រើនគួរឱ្យកត់សម្គាល់នៃកិច្ចសហប្រតិបត្តិការជាង ៥០ឆ្នាំ កន្លងមក នៅក្រោមក្របខណ្ឌនៃកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ាន ព្រមទាំងរំពឹងថា យើងនឹងអាចសម្រេចបាននូវកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ប្រកបដោយនិរន្តភាពមួយ ក្នុងគោលបំណងកសាងកម្លាំងពលកម្មក្នុងតំបន់អាស៊ានដែលមានភាពធន់ និងថាមវន្ត។

(អនុម័ត)

*បកប្រែក្រៅផ្លូវការ*

៣. ដើម្បីចូលរួមអបអរសាទរព្រោះពេលខួបលើកទី៥០ នៃកិច្ចសហប្រតិបត្តិការក្រោមក្របខណ្ឌនៃកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ាន យើងបានដាក់ចេញនូវសមិទ្ធផលជាតំណាងនៃការរំលឹកខួបចំនួន ២ គឺ វីដេអូរំលឹកខួបនៃកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ាន (Commemorative Video) និងវត្ថុរំលឹកអនុស្សាវរីយ៍ (Time Capsule)។ វីដេអូរំលឹកខួបនៃកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ាន (Commemorative Video) និងវត្ថុរំលឹកវត្ថុរំលឹកអនុស្សាវរីយ៍ (Time Capsule) មានគោលបំណងរំលេចពីព្រឹត្តិការណ៍សំខាន់ៗ គម្រោងនានា និងសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការការងារអាស៊ានក្នុងរយៈពេល ៥ ទសវត្សរ៍ចុងក្រោយនេះ។ តាមរយៈវីដេអូ និងវត្ថុរំលឹកអនុស្សាវរីយ៍នេះ យើងបានឆ្លុះបញ្ចាំងពីបញ្ហាប្រឈមដែលកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានជួបប្រទះ អំឡុងពេលនៃការបង្កើតឡើងនៃកិច្ចប្រជុំ និងកិច្ចសហប្រតិបត្តិការប្រកបដោយភាពទូលំទូលាយ និងភាពស៊ីជម្រៅ ចាប់តាំងពីឆ្នាំ១៩៧៥។ ទាំងនេះ បានរំលឹកពីការប្តេជ្ញាយ៉ាងមុតមាំរបស់យើងក្នុងការសម្រេចបាននូវគោលបំណងរបស់កិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានសម្រាប់ភាពប្រសើរឡើងនៃគុណភាពជីវិតរបស់កម្លាំងពលកម្មក្នុងតំបន់អាស៊ាន តាមរយៈការលើកកម្ពស់សុវត្ថិភាព និងការងារសមរម្យ។

៤. យើងបានបង្ហាញពីការគាំទ្រ ចំពោះការអភិវឌ្ឍចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០៤៥ និងបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការពង្រឹងវិធីសាស្ត្ររួមនានា និងកិច្ចសហប្រតិបត្តិការមុខរបរ និងការងារនៅក្នុងផែនការយុទ្ធសាស្ត្រសហគមន៍សង្គម-វប្បធម៌អាស៊ាន ក្រោយឆ្នាំ២០២៥ (ASCC)។

៥. យើងមានភាពសោមនស្សនឹងការអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងវៀងចន្ទន៍ ស្តីពីការបម្លាស់ទី ការទទួលស្គាល់ និងការអភិវឌ្ឍជំនាញសម្រាប់ពលករទេសន្តរប្រវេសក៍ និងបញ្ជីត្រួតពិនិត្យ នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៤ និង៤៥។ សេចក្តីថ្លែងការណ៍នេះ បានបង្ហាញពីការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការពង្រឹង និងលើកកម្ពស់យន្តការទទួលស្គាល់ជំនាញរបស់ពលករទេសន្តរប្រវេសក៍អាស៊ាន។ យើងសម្លឹងទៅការប្រើប្រាស់ដោយស្ម័គ្រចិត្តនៃបញ្ជីត្រួតពិនិត្យដោយរដ្ឋសមាជិកអាស៊ានចាប់ពីឆ្នាំ២០២៥ ដើម្បីវាយតម្លៃវឌ្ឍនភាពរបស់យើងក្នុងការអនុវត្តសេចក្តីថ្លែងការណ៍នេះ។

៦. យើងក៏មានភាពសោមនស្សជាមួយនឹងការអនុម័តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការទប់ស្កាត់ពលកម្មកុមារ រួមទាំងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ៤៤ និង៤៥។ សេចក្តីថ្លែងការណ៍នេះ បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តដ៏ខ្ជាប់ខ្ជួនរបស់យើងក្នុងការការពារកុមារក្នុងតំបន់អាស៊ាន និងប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ ជាពិសេសក្នុងទម្រង់ធ្ងន់ធ្ងរ

បំផុត។ យើងបានប្រគល់ភារកិច្ចឱ្យកិច្ចប្រជុំឧត្តមមន្ត្រីការងារ (SLOM) ដោយសហការជាមួយគណៈកម្មការអាស៊ាន ស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ព្រមទាំងអង្គភាព និងស្ថាប័នពាក់ព័ន្ធតាមវិស័យអាស៊ាន ដើម្បីអនុវត្តសេចក្តីថ្លែងការណ៍នេះ តាមរយៈផែនទីបង្ហាញផ្លូវអាស៊ាន ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រឹមឆ្នាំ២០២៥ និងផែនទីបង្ហាញផ្លូវជាបន្តបន្ទាប់។

៧. យើងបានអនុម័តគោលការណ៍ណែនាំអាស៊ាន ស្តីពីចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសក៍ក្នុងតំបន់អាស៊ាន ដែលជាឯកសារណែនាំដោយមិនជាប់កាតព្វកិច្ចសម្រាប់រដ្ឋសមាជិកអាស៊ាន ក្នុងការពិចារណាលើកិច្ចព្រមព្រៀងសន្តិសុខសង្គមទ្វេភាគី ឬពហុភាគី ឬទម្រង់ផ្សេងទៀតនៃការសម្របសម្រួលសន្តិសុខសង្គម។ យើងបានប្រគល់ភារកិច្ច ទៅឱ្យកិច្ចប្រជុំឧត្តមមន្ត្រីការងារ (SLOM) ដោយសហការជាមួយគណៈកម្មការអាស៊ាន ស្តីពីការលើកកម្ពស់ និងការពារសិទ្ធិពលករទេសន្តរប្រវេសក៍ (ACWC) ដើម្បីអនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសក៍ក្នុងតំបន់អាស៊ាន ឱ្យបានពេញលេញតាមរយៈគោលការណ៍ណែនាំរបស់ខ្លួន។ យើងក៏បានអនុម័តគោលការណ៍ណែនាំអាស៊ាន ស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសក៍នេសាទ ដែលជាគោលការណ៍ណែនាំ ដោយមិនជាប់កាតព្វកិច្ចសម្រាប់ការពង្រឹងលក្ខខណ្ឌការងារ និងការការពារពលករទេសន្តរប្រវេសក៍នេសាទ ជាពិសេសពលករនៅលើកប៉ាល់នេសាទ ព្រមទាំងបញ្ជ្រាបការការពាររបស់ពួកគេនៅក្នុងគោលនយោបាយ និងយន្តការពាក់ព័ន្ធទាំងអស់។ យើងស្វាគមន៍ការវាយតម្លៃដោយឯករាជ្យលើកទី៣ នៃការអនុវត្តគោលការណ៍កុងសង់ស៊ីសអាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ ដោយគណៈកម្មការអាស៊ាន ស្តីពីការអនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ (ACWC) នៅក្នុង ២០២៦។

៨. យើងបានកត់សម្គាល់ប្រកបដោយសេចក្តីពេញចិត្តចំពោះវឌ្ឍនភាពនៃការអនុវត្តកម្មវិធីការងាររបស់រដ្ឋមន្ត្រីការងារអាស៊ានសម្រាប់ឆ្នាំ២០២១-២០២៥ រួមទាំងផែនការការងាររបស់គណៈកម្មការ ACMW កិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការងារអាស៊ាន (SLOM-WG) កិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលនៃបណ្តាញសុវត្ថិភាព និងសុខភាពការងារអាស៊ាន (ASEAN-OSHNET) និងកិច្ចប្រជុំគណៈកម្មការអធិការកិច្ចការងារអាស៊ាន (ALICOM)។ យើងបានប្រគល់ភារកិច្ចឱ្យ SLOM និងស្ថាប័នបុត្រសម្ព័ន្ធរបស់ខ្លួនធ្វើការឆ្ពោះទៅរកការបញ្ចប់ផែនការការងារទាំងនេះឱ្យបានទាន់ពេលវេលានៅចុង

(អនុម័ត)

*បកប្រែក្រៅផ្លូវការ*

ឆ្នាំ២០២៥ និងបង្កើតកម្មវិធីការងាររដ្ឋមន្ត្រីការងារអាស៊ានឆ្នាំ២០២៦-២០៣០ ប្រកបដោយបរិយាបន្ន មានភាពឆ្លើយតប និងមានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការងារសមរម្យសម្រាប់ពលករទាំងអស់។

៩. យើងសូមកោតសរសើរដល់សហគ្រាសចំនួន ១៨ មកពីរដ្ឋសមាជិកអាស៊ាន ដែលបានទទួលពានរង្វាន់ ASEAN-OSHNET លើកទី៥ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤ នៅប្រទេសសិង្ហបុរី ចំពោះសមិទ្ធផល និងការអនុវត្តល្អក្នុងការសម្រេចបាននូវកន្លែងការងារប្រកបដោយសុវត្ថិភាព និងសុខភាពល្អ។ យើងអបអរសាទរសហគ្រាសចំនួន ៥ មកពីរដ្ឋសមាជិកអាស៊ាន ដែលបានទទួលពានរង្វាន់ខ្សែបូក្រហមអាស៊ានលើកទី៥ សម្រាប់កន្លែងការងារឆ្នើម (5th ARROW Award) សម្រាប់កម្មវិធីនៅកន្លែងធ្វើការរបស់ពួកគេ ដើម្បីការពារ និងគ្រប់គ្រងមេរោគអេដស៍ និងបង្កើតបរិយាកាសមិនមានការរើសអើងសម្រាប់ពលករផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។

១០. យើងត្រូវបានលើកទឹកចិត្ត ដោយការអភិវឌ្ឍរចនាសម្ព័ន្ធប្រកបដោយស្ថិរភាព នៃក្រុមប្រឹក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈអាស៊ាន (ATC) ចាប់តាំងពីការបង្កើតឡើងក្នុងឆ្នាំ២០២០។ យើងបានប្រគល់ភារកិច្ចឱ្យ ATC ក្នុងការពង្រឹងទំនាក់ទំនង និងភាពជាដៃគូរបស់ខ្លួនជាមួយស្ថាប័នតាមវិស័យអាស៊ាន ដៃគូសន្ទនា អង្គការអន្តរជាតិ និងភាគីពាក់ព័ន្ធឆ្ពោះទៅរកការរីកចម្រើននៃ TVET និងការរៀនសូត្រពេញមួយជីវិតនៅក្នុងតំបន់។ យើងបានកត់សម្គាល់ពីការបញ្ចប់នៃគម្រោងការសិក្សាវាយតម្លៃ ដែលជាសកម្មភាពតាមដានសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការអភិវឌ្ឍធនធានមនុស្សសម្រាប់ការប្រែប្រួលពិភពនៃការងារ។ របាយការណ៍ ស្តីពីការសិក្សាវាយតម្លៃនៃការបង្កើតមូលនិធិនេះ បង្ហាញពីភាគីពាក់ព័ន្ធសំខាន់ៗលើការអភិវឌ្ឍធនធានមនុស្សក្នុងអាស៊ាន និងបង្ហាញពីម៉ូឌែលផ្សេងៗសម្រាប់មូលនិធិអភិវឌ្ឍធនធានមនុស្សក្នុងតំបន់។

១១. យើងសូមកោតសរសើរចំពោះការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់នៃសន្ទស្សន៍ផលិតភាពការងារក្នុងតំបន់អាស៊ាន ស្ថិតិមុខរបរ និងការងារក្រៅប្រព័ន្ធរបស់អាស៊ាន និងទិន្នន័យសម្រាប់សូចនាករលទ្ធផលសំខាន់ៗនៃផែនទីបង្ហាញផ្លូវអាស៊ាន ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារត្រឹមឆ្នាំ២០២៥ និងផែនទីបង្ហាញផ្លូវនៃសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការអភិវឌ្ឍធនធានមនុស្សសម្រាប់ការប្រែប្រួលពិភពនៃការងារ។ យើងបានកត់សម្គាល់បញ្ជីត្រួតពិនិត្យ ដែលបានបំពេញរួចរាល់ នៃគោលការណ៍ណែនាំអាស៊ាន ស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយមុខរបរ និងការងារ

(អនុម័ត)

*បកប្រែក្រៅផ្លូវការ*

ឆ្ពោះទៅរកការងារសមរម្យសម្រាប់ទាំងអស់គ្នាក្នុងឆ្នាំ២០២២ និង២០២៤ និងជាព័ត៌មានមានប្រយោជន៍ ស្តីពីសមិទ្ធផល ដើម្បីសម្រេចបាននូវសមភាពយេនឌ័រទូទាំងតំបន់។

១២. យើងបានកោតសរសើរដល់ SLOM និងស្ថាប័នបុគ្រសម្ព័ន្ធសម្រាប់ការបញ្ចប់ការសិក្សាក្នុងតំបន់ផ្សេងៗ ដែលផ្តល់នូវការយល់ដឹងដ៏មានប្រយោជន៍ និងផ្តល់ជាអនុសាសន៍គោលនយោបាយ។ ការសិក្សាទាំងនេះ បានដោះស្រាយបញ្ហាទូទៅ ដូចជាការការពារអ្នកធ្វើការតាមថ្នាលបច្ចេកវិទ្យា (Platform workers), ច្បាប់ និងគោលនយោបាយរបស់ពលករទេសន្តរប្រវេសក៍ជាស្ត្រី, ប្រសិទ្ធភាពនៃប្រព័ន្ធព័ត៌មានទីផ្សារការងារ, កម្មវិធីសិក្សា TVET ដែលមានភាពឆ្លើយតប ការកែលម្អកិច្ចខិតខំប្រឹងប្រែងលើសុវត្ថិភាព និងសុខភាពការងារ, កិច្ចសន្យាការងាររបស់ពលករទេសន្តរប្រវេសក៍, ការធ្វើសមាហរណកម្មឡើងវិញនៃពលករទេសន្តរប្រវេសក៍ក្នុងពេលមានវិបត្តិ (ដូចជាអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩) និងទំនាក់ទំនងនៃការប្រែប្រួលអាកាសធាតុ និងការបម្លាស់ទីមនុស្ស ក្នុងចំណោមកត្តាផ្សេងៗទៀត។ យើងបានលើកទឹកចិត្ត SLOM ឱ្យប្រើប្រាស់ព័ត៌មានជាមតិក្នុងការកែលម្អការរៀបចំតារាងអាទិភាពក្រោយឆ្នាំ២០២៥ នៃកិច្ចសហប្រតិបត្តិការអាស៊ានក្នុងវិស័យការងារ។ យើងបានស្នើសុំឱ្យលេខាធិការដ្ឋានអាស៊ាន បន្តការបោះពុម្ពផ្សាយជាបន្តបន្ទាប់ស្តីពីទស្សនវិស័យទេសន្តរប្រវេសន៍អាស៊ាន និងទស្សនវិស័យមុខរបរ និងការងារអាស៊ាន ដែលនឹងគាំទ្រដល់រដ្ឋសមាជិកអាស៊ានក្នុងការយល់ដឹងឱ្យកាន់តែប្រសើរឡើង និងការដោះស្រាយបញ្ហាការងារដែលកំពុងកើតមាននៅក្នុងតំបន់។

១៣. យើងបានកោតសរសើរ និងលើកទឹកចិត្តក្នុងការបន្តកិច្ចសហប្រតិបត្តិការជាមួយប្រទេសបូកបី, អូស្ត្រាលី, កាណាដា, សហរដ្ឋអាម៉េរិក, សហភាពអឺរ៉ុប, អាល្លឺម៉ង់, ស្វីស, និងដៃគូអាស៊ាន និងភាគីពាក់ព័ន្ធអាស៊ានផ្សេងៗទៀត ក្នុងការកសាងសហគមន៍អាស៊ានដែលមានភាពធន់ នវានុវត្តន៍ ថាមវន្ត និងផ្តោតលើប្រជាជន។

១៤. យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលនៃប្រទេសសិង្ហបុរី ជាពិសេសក្រសួងហត្ថកម្ម ចំពោះបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ និងការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ាន លើកទី២៨ (28th ALMM) ដ៏ល្អឥតខ្ចោះ។ យើងក៏សូមថ្លែងអំណរគុណដល់លេខាធិការដ្ឋានអាស៊ានសម្រាប់ការគាំទ្រឥតឈប់ឈរក្នុងការរៀបចំសម្រាប់កិច្ចប្រជុំ និងអំឡុងពេលកិច្ចប្រជុំ។

១៥. យើងបានយល់ព្រមជួបគ្នាម្តងទៀត នៅឆ្នាំ២០២៦ ក្រោមអាណត្តិភាពជាប្រធាននៃកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានរបស់ប្រទេសថៃ។